**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)**
**លេខាធិការដ្ឋាន**

លេខ: ០៤៦ សជណ/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧

**គោរពជូន**
**ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** ៖ ស្តីពីការបង់ប្រាក់សមាជិកភាពជូនសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់នៅតាមរាជធានី ខេត្ត។

**យោង** ៖ -សេចក្តីជូនដំណឹងលេខ០៥៤ សជណ/គ.ជ.អ.ប ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
-ស្មារតីអង្គប្រជុំថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ រវាងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា បន្ទាប់ពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដាក់ចេញសេចក្តីជូនដំណឹងលេខ ០៥៤ សជណ/គ.ជ.អ.ប ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ ស្តីពីការអនុញ្ញាតឱ្យក្រុមប្រឹក្សាក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់ថវិការបស់រដ្ឋបាលក្រុង ស្រុក និងថវិកាឃុំ សង្កាត់ សម្រាប់បង់ប្រាក់សមាជិកភាពជូនសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់នៅតាមរាជធានី ខេត្ត លេខាធិការដ្ឋាន គ.ជ.អ.ប សង្កេតឃើញថាការអនុវត្តសេចក្តីជូនដំណឹងនេះមានភាពខុសៗគ្នាលើមូលដ្ឋានគណនាប្រាក់បង់សមាជិកភាពប្រចាំឆ្នាំជូនសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់នៅតាមរាជធានី ខេត្ត។

ដូច្នេះដើម្បីធានានូវភាពលូនក្នុងការអនុវត្តសេចក្តីជូនដំណឹងខាងលើ លេខាធិការដ្ឋាន គ.ជ.អ.ប សូមធ្វើការណែនាំដល់ក្រុមប្រឹក្សាក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ ដោយអនុញ្ញាតឱ្យប្រើប្រាស់ថវិការដ្ឋបាលក្រុង ស្រុក និងថវិកាឃុំ សង្កាត់ចំនួន ២% នៃថវិកាផ្នែករដ្ឋបាល (ថវិការដ្ឋបាលដែលរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ទទួលបានពីវិភាជន៍សមាសភាគរដ្ឋបាលនៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ប្រចាំឆ្នាំតែប៉ុណ្ណោះ) ដោយដកចេញបន្ទុកបុគ្គលិកដែលគ្រោងក្នុងជំពូក៦៤ ដោយមិនរាប់បញ្ចូលនូវមន្ត្រីកិច្ចសន្យាសម្រាប់ការបង់ប្រាក់សមាជិកភាពជូនសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអភិបាលរាជធានី ខេត្តមេត្តាជ្រាប និងណែនាំដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធ ឱ្យអនុវត្តស្របតាមខ្លឹមសារនៃលិខិតណែនាំនេះតាមការគួរ។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានអំពីខ្ញុំ ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**សក់ សេដ្ឋា**

*ចម្លងជូន៖*
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-អគ្គនាយកដ្ឋានរតនាគារជាតិ
-សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
-ឯកសារ-កាលប្បវត្តិ

# បច្ចុប្បន្នភាពចំនួនរាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក ឃុំ សង្កាត់ និងភូមិ

## នៅព្រះរាជាណាចក្រកម្ពុជា

| ល.រ | រាជធានី ខេត្ត | ខណ្ឌ | ក្រុង | ស្រុក | សរុប ខ.ក.ស្រ | សង្កាត់ | ឃុំ | សង្កាត់ បង្កើតថ្មី | ឃុំ បង្កើតថ្មី | សរុប ឃ.ស | ចំនួនភូមិ ភូមិចាស់ | ភូមិថ្មី | សរុប ចំនួនភូមិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | | ២ | ៧ | ៩ | ១០ | ៥៥ | | | ៦៥ | ៦៥៦ | ២ | ៦៥៨ |
| ២ | បាត់ដំបង | | ១ | ១៣ | ១៤ | ១០ | ៩២ | | | ១០២ | ៧៩៩ | ១០ | ៨០៩ |
| ៣ | កំពង់ចាម | | ១ | ៩ | ១០ | ៤ | ១០៥ | | | ១០៩ | ៨៩៤ | | ៨៩៤ |
| ៤ | កំពង់ឆ្នាំង | | ១ | ៧ | ៨ | ៤ | ៦៥ | | ១ | ៧០ | ៥៦០ | ៩ | ៥៦៩ |
| ៥ | កំពង់ស្ពឺ | | ១ | ៧ | ៨ | ៥ | ៨២ | | | ៨៧ | ១៣៤៩ | ១៩ | ១៣៦៨ |
| ៦ | កំពង់ធំ | | ១ | ៧ | ៨ | ៨ | ៧៣ | | | ៨១ | ៧៤៩ | ១៦ | ៧៦៥ |
| ៧ | កំពត | | ១ | ៧ | ៨ | ៥ | ៨៨ | | | ៩៣ | ៤៨៨ | | ៤៨៨ |
| ៨ | កណ្ដាល | | ១ | ១០ | ១១ | ៦ | ១២១ | | | ១២៧ | ១០១០ | | ១០១០ |
| ៩ | កោះកុង | | ១ | ៦ | ៧ | ៣ | ២៦ | | | ២៩ | ១១៨ | ២ | ១២០ |
| ១០ | ក្រចេះ | | ១ | ៥ | ៦ | ៥ | ៤១ | | ១ | ៤៧ | ២៥៣ | ៥ | ២៥៨ |
| ១១ | មណ្ឌលគិរី | | ១ | ៤ | ៥ | ៤ | ១៧ | | | ២១ | ៩០ | ២ | ៩២ |
| ១២ | រាជធានីភ្នំពេញ | ១២ | | | ១២ | ៩៦ | | ៩ | | ១០៥ | ៩០៩ | ៤៤ | ៩៥៣ |
| ១៣ | ព្រះវិហារ | | ១ | ៧ | ៨ | ២ | ៤៩ | | | ៥១ | ២២៩ | ៣ | ២៣២ |
| ១៤ | ព្រៃវែង | | ១ | ១២ | ១៣ | ៣ | ១១៣ | | | ១១៦ | ១១៣៧ | ១២ | ១១៤៩ |
| ១៥ | ពោធិ៍សាត់ | | ១ | ៥ | ៦ | ៧ | ៤២ | | | ៤៩ | ៥០៧ | ៤ | ៥១១ |
| ១៦ | រតនគិរី | | ១ | ៨ | ៩ | ៤ | ៤៦ | | | ៥០ | ២៤៣ | | ២៤៣ |
| ១៧ | សៀមរាប | | ១ | ១១ | ១២ | ១៣ | ៨៧ | | | ១០០ | ៨៧៦ | ៣៤ | ៩១០ |
| ១៨ | ព្រះសីហនុ | | ១ | ៣ | ៤ | ៥ | ២២ | ១ | ១ | ២៩ | ១១០ | | ១១០ |
| ១៩ | ស្ទឹងត្រែង | | ១ | ៤ | ៥ | ៤ | ៣០ | | | ៣៤ | ១២៨ | | ១២៨ |
| ២០ | ស្វាយរៀង | | ២ | ៦ | ៨ | ១២ | ៦៨ | | | ៨០ | ៦៩០ | | ៦៩០ |
| ២១ | តាកែវ | | ១ | ៩ | ១០ | ៣ | ៩៧ | | | ១០០ | ១១១៩ | | ១១១៩ |
| ២២ | ឧត្ដរមានជ័យ | | ១ | ៤ | ៥ | ៥ | ១៩ | | | ២៤ | ២៨៦ | ១៨ | ៣០៤ |
| ២៣ | កែប | | ១ | ១ | ២ | ៣ | ២ | | | ៥ | ១៨ | | ១៨ |
| ២៤ | ប៉ៃលិន | | ១ | ១ | ២ | ៤ | ៤ | | | ៨ | ៧៩ | ១១ | ៩០ |
| ២៥ | ត្បូងឃ្មុំ | | ១ | ៦ | ៧ | ២ | ៦២ | | | ៦៤ | ៨៨៧ | ៨ | ៨៩៥ |
| | សរុប | ១២ | ២៦ | ១៥៩ | ១៩៧ | ២២៧ | ១៤០៦ | ១០ | ៣ | ១៦៤៦ | ១៤១៨៤ | ១៩៩ | ១៤៣៨៣ |